ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ

## អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍

# Statue of the Action for Research and Development

# បុព្វកថា

ក្រោយពីព្រះរាជាណាចក្រកម្ពុជា បានឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃផ្ទៃក្នុងប្រទេសអស់ជាច្រើនទសវត្សរ៍កន្លងមក ការកសាង ស្តារ និងអភិវឌ្ឍន៍ជាតិមាតុភូមិឡើងវិញ ត្រូវបានចាប់ផ្តើមឡើងយ៉ាងផុសផុល តាមរយៈការជួយខ្នះខ្នែងជាស្មារតី សំភារៈ ថវិកាពីប្រភពជំនួយនានាទាំងក្នុង និងក្រៅប្រទេស ។ ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជាតិប្រកបដោយប្រសិទ្ធិភាព គឺចាំបាច់ត្រូវមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ជាពិសេសលើផ្នែកធនធានបញ្ញា ស្មារតី ដែលយើងត្រូវតែផ្តល់អាទិភាពដំបូងបំផុត ។

ដោយយល់ឃើញថាការបណ្តុះបណ្តាលធនធានមនុស្ស ជាកត្តាចំបង ដើម្បីកសាងសមត្ថភាពឈានទៅរកការចូលរួមប្រកបដោយគុណភាពក្នុងការកសាង ស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិ

ដោយយល់ឃើញថាស្រទាប់យុវវ័យ សិស្សានុសិស្ស និស្សិត មជ្ឈដ្ឋានអ្នកសិក្សា ស្រាវជ្រាវ ជាសសរទ្រូង និងជាស្នូលដ៏សំខាន់ដើម្បីអោយល្បឿន និងគោលបំណងនៃការអភិវឌ្ឍន៍ប្រទេសជាតិឈានទៅសំរេចបានជោគជ័យឆាប់រហ័ស

ដោយយល់ឃើញថានាពេលបច្ចុប្បន្ននេះ មានការប្រកួតប្រជែងយ៉ាងស្វិតស្វាញឈរលើស្មារតីទទួលខុសត្រូវ និងម្ចាស់ការក្នុងការវិវត្តន៍ឥតឈប់ឈរផ្នែកវិទ្យាសាស្ត្រ សមត្ថភាព បញ្ញា ស្មារតី ទាំងក្នុង និងក្រៅប្រទេស

យើងខ្ញុំទាំងអស់គ្នា ដែលធ្លាប់ឆ្លងកាត់នូវការសិក្សារៀនសូត្រ ស្រាវជ្រាវ និងបទពិសោធន៍ក្នុងមួយរយៈកាលកន្លងមក តាមរយៈការសិក្សានៅតាមសាកលវិទ្យាល័យ ការបណ្តុះបណ្តាលស្រាវជ្រាវនៅតាមបណ្តាស្ថាប័នអង្គភាព ព្រមទាំងការបំពេញការងារជាមួយអង្គការមិនមែនរដ្ឋាភិបាលនានាជាច្រើន បានយល់ពីតំរូវការពិតប្រាកដរបស់សង្គមកម្ពុជា គឺការទាមទារយ៉ាងទទូចអោយទទួលបាននូវការបង្កើតនូវសមត្ថភាពអភិវឌ្ឍន ដ៏ច្បាស់លាស់សំរាប់អនាគតរបស់ខ្លួន យើងខ្ញុំទាំងអស់បានសំរេចចិត្តជាឯកច្ឆ័ន្ទ ដោយឈរលើមូលដ្ឋាននៃច្បាប់រដ្ឋធម្មនុញ្ញ របស់ព្រះរាជាណាចក្រកម្ពុជា ដែលបានចែងនៅក្នុងមាត្រា ៤២ ជំពូក៣ ស្តីអំពីសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋខ្មែរ នៅក្នុងការបង្កើតអង្គការ សមាគម ដូច្នេះទើបរួមគ្នាបង្កើតជាអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលមានចរិតលក្ខណៈ និង លក្ខន្តិកៈដូចខាងក្រោមនេះ :

## ជំពូក ១

## អត្តសញ្ញាណ

### មាត្រា ១ : ឈ្មោះ និងបាវចនាផ្លូវការរបស់អង្គការ

**'អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍'** គឺជាឈ្មោះផ្លូវការរបស់អង្គការជាភាសាខ្មែរ និង **Action for Research and Development** គឺជាឈ្មោះអង្គការជាភាសាអង់គ្លេស ដែលសរសេរកាត់ថា **ARD** ។

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ មានបាវចនារបស់ខ្លួនគឺ **សមត្ថភាព គុណភាព តម្លាភាព** ដែលជាការឆ្លុះបញ្ចាំងអោយឃើញពីការតាំងចិត្ត និងទទួលខុសត្រូវខ្ពស់របស់អង្គការ នៅក្នុងការបំពេញបេសកកម្មដើម្បីអោយទទួលបាននូវលទ្ធផលជាទីគាប់ចិត្តសំរាប់គ្រប់មជ្ឈដ្ឋានគោលដៅ និងជាគំរូល្អសំរាប់ការអនុវត្តន៏តាម ។

### មាត្រា ២ : អាសយដ្ឋានរបស់អង្គការ

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ មានការិយាល័យបណ្តោះអាសន្ន តាំងនៅអាសយដ្ឋានផ្ទះលេខ តេ ៧៤ (T 74) សង្កាត់ទន្លេបាសាក់ ខ័ណចំការមន រាជធានីភ្នំពេញ ។ ការិយាល័យនេះ អាចផ្លាស់ប្តូរទីតាំងបាន ដោយយោងទៅតាមស្ថានការជាក់ស្តែង និងអាចបង្កើតការិយាល័យដែលជាសាខានៅតាមបណ្តាខេត្តក្រុងនានាក្នុងប្រទេសទៅតាមការចាំបាច់ ។

### មាត្រា ៣ : សញ្ញាសំគាល់ អត្ថន័យ និងត្រារបស់អង្គការ

សញ្ញាសំគាល់របស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ មានរាងជារង្វង់ ដែលមាន :

- រូបសៀវភៅមួយក្បាលនៅចំកណ្តាលរង្វង់ មានសរសេរអក្សរជាភាសាអង់គ្លេសថា **ARD** ជានិមិត្តរូប នៃការយល់ដឹងទូទៅ សមត្ថភាព និងលទ្ធភាពជំនាញក្នុងអាជីពចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋកម្ពុជា ឆ្លងកាត់តាមរយៈការបណ្តុះបណ្តាល ស្រាវជ្រាវប្រកបដោយភាពតស៊ូ អំណត់ និងព្យាយាម ។
- នៅជុំវិញសៀវភៅ ពេញផ្ទៃរង្វង់ទាំងមូល គឺជារូបវាលស្រែ និងដើមឈើមួយចំនួន ដែលជានិមិត្តរូបបញ្ជាក់ពីនិរន្តរភាពនៃផលិតផលកសិកម្ម និងធនធានធម្មជាតិ បរិស្ថាន ដ៏សម្បូរបែបប្រកបដោយគុណភាព និងសុវត្ថិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- នៅផ្នែកខាងលើនៃរង្វង់ មានសរសេរអក្សររាងកោងចុះក្រោមជាភាសាខ្មែរថា អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ និងសរសេរជាភាសាអង់គ្លេសនៅផ្នែកខាងក្រោមនៃរង្វង់ រាងកោងឡើងលើថា **Action for Research and Development** ។

ត្រារបស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ មានរាងមូល និងមានវិជ្ជមាត្រប្រវែង ៣៩សង្ទីម៉ែត្រ ដែលមានសញ្ញាសំគាល់អង្គការ នៅចំកណ្តាល ។ នៅចន្លោះកណ្តាល នៃខ្សែរវ័ណ្ឌជារង្វង់របស់ត្រា

មានសរសេរអក្សរព័ទ្ធជុំវិញជាភាសាខ្មែរនៅ ផ្នែកខាងលើថា អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ និងជាភាសាអង់គ្លេសនៅផ្នែកខាងក្រោមថា **Action for Research and Development**។ ការបោះត្រាសំគាល់ជាផ្លូវការ នៃអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ គឺប្រើប្រាស់ពណ៌បៃតង ដែលជាតំណាងអោយបរិស្ថានដ៏បរិសុទ្ធសំរាប់ការរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិនៅលើផែនដី ។

សញ្ញាសំគាល់ របស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ មានភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធ១ ។

## ជំពូក ២
## គោលការណ៍ ឧត្តមគតិ បេសកកម្ម និងសកម្មភាពការងារ

### មាត្រា ៤ : គោលការណ៍

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមានលក្ខណៈឯករាជ្យ អព្យាក្រិត និងមិនពាក់ព័ន្ធជាមួយគណបក្សនយោបាយឡើយ ។

អង្គការ នឹងសហការជាមួយគ្រប់ស្ថាប័ន អង្គភាព សមាគមជាតិ និងអន្តរជាតិនានា ក្នុងគោលបំណងបំរើផលប្រយោជន៍ប្រទេសជាតិជាធំ។

អង្គការដំណើរការ និងបន្តនិរន្តរភាពរបស់ខ្លួនតាមរយៈការបំរើសេវាកម្មបណ្តុះបណ្តាល ស្រាវជ្រាវ ចងក្រង និងបោះពុម្ពផ្សាយឯកសារ ព្រមទាំងទទួលជំនួយនានាពីបណ្តាប្រភពផ្សេងៗទាំងក្នុង និងក្រៅប្រទេស ដែលស្របទៅតាមលក្ខន្តិកៈរបស់អង្គការ។

### មាត្រា ៥ : ឧត្តមគតិ

សង្គមកម្ពុជាមួយ ដែលប្រជាពលរដ្ឋមានសមត្ថភាពប្រកបដោយគុណភាព និងប្រសិទ្ធិភាព ចេះជួយគ្នាទៅវិញទៅមក ព្រមទាំងរស់នៅក្នុងជីវភាពមួយដែលមានលក្ខណៈថ្លៃថ្នូរ ពោរពេញទៅដោយបរិស្ថានល្អ។

### មាត្រា ៦ : បេសកកម្ម

សមត្ថភាព និងគុណភាពរបស់និស្សិត និងប្រជាពលរដ្ឋក្នុងសហគមន៍ជនបទត្រូវបានបង្កើន ដែលនាំអោយពួកគេអាចចូលរួមចំណែកប្រកបដោយប្រសិទ្ធិភាពនៅក្នុងការអភិវឌ្ឍន៍សង្គមកម្ពុជា ប្រកបដោយនិរន្តរភាព តាមរយៈការផ្តល់អំណាច និងធ្វើការជាមួយប្រជាកសិករក្រីក្រនៅតំបន់ជនបទ ។

### មាត្រា ៧ : កម្មវិធីរបស់អង្គការ

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ អនុវត្តកម្មវិធីចំបងរបស់ខ្លួន ដូចខាងក្រោម

**១. កម្មវិធីកសាងសមត្ថភាព, ស្រាវជ្រាវ និងបោះពុម្ព ៖**

គឺជាកម្មវិធីដែលមានគោលដៅបង្កើត និងបង្កើននូវសមត្ថភាពប្រកបដោយគុណភាព ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសដល់យុវនិស្សិត ដែលជាបង្អែកដ៏សំខាន់នៅក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ ការបណ្តុះបណ្តាលមុខជំនាញខ្លីៗ ការចុះស្រាវជ្រាវ ការបោះពុម្ពឯកសារជំនួយស្មារតី ការបង្កើតបណ្ណាល័យ សិក្ខាសាលា វីព្រឹត្តិការណ៍ពិសេសៗ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងតំរូវការជាក់ស្តែងរបស់ក្រុមគោលដៅ និងសង្គមជាតិ ដោយផ្តោតជាអាទិភាពចំពោះការងារអភិវឌ្ឍន៍សហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន, អភិបាលកិច្ចល្អ និងការលើកស្ទួយសេដ្ឋកិច្ចគ្រួសារ ។

**២. កម្មវិធីអភិវឌ្ឍន៍សហគមន៍ និងការគ្រប់គ្រងប្រកបដោយនិរន្តរភាព ៖**

គឺជាកម្មវិធីដែលមានគោលដៅចូលរួមកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋរស់នៅតាមតំបន់ជនបទតាមរយៈការបណ្តុះបណ្តាល-ផ្សព្វផ្សាយបច្ចេកទេសកសិកម្មសមស្រប ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព និងការចងក្រងក្រុមកសិករ-សហគមន៍ ដោយផ្តល់នូវសិទ្ធិអំណាចពេញលេញ ក្នុងការធ្វើសេចក្តីសំរេចចិត្តនានា ក្នុងគោលដៅលើកស្ទួយក៏រិតជីវភាពរស់នៅរបស់គ្រួសារ និងសហគមន៍របស់ខ្លួន ។

គោលគំនិត នៃការលើកស្ទួយយេនឌ័រនៅក្នុងអង្គការ និងក្រុមគោលដៅ ( គ្រួសារ និងសហគមន៍ ) ត្រូវបានប្រកាន់ខ្ជាប់ជានិច្ច នៅក្នុងការអនុវត្តន៍កម្មវិធីនានារបស់អង្គការសកម្មភាពដើម្បី ស្រាវជ្រាវ និងអភិវឌ្ឍន៍ ។

## ជំពូក ៣
## រចនាសម្ព័ន្ធគ្រប់គ្រង និងដឹកនាំ

### មាត្រា ៨ ៖ យន្តការគ្រប់គ្រង

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ គ្រប់គ្រងដំណើរការសកម្មភាពរបស់ខ្លួនតាមរយៈការបង្កើតឡើងនូវយន្តការសំខាន់ពីរ គឺក្រុមប្រឹក្សាពិគ្រោះយោបល់ **Advisory Board** និងគណៈកម្មាធិការប្រតិបត្តិ **Executive Committee** ។

### មាត្រា ៩ ៖ ភារកិច្ច និងសមាសភាពរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់

១. ក្រុមប្រឹក្សាពិគ្រោះយោបល់ **Advisory Board** មានតួនាទីជាអ្នកបង្ហាញទិសដៅ ផ្តល់គំនិត និងការប្រឹក្សាទៅលើផ្នែកគោលនយោបាយ យុទ្ធសាស្ត្ររៀបចំផែនការ និងបង្ហាញផ្លូវក្នុងការទំនាក់ទំនង និងសំរបសំរួលជាមួយប្រភពផ្តល់ជំនួយ។ ក្រុមប្រឹក្សាពិគ្រោះយោបល់ ត្រូវបានទទួលនូវ

របាយការណ៍រីកចំរើនផ្នែកសកម្មភាព និងផ្នែកថវិកា ជាទៀងទាត់រៀងរាល់មួយត្រីមាសម្តង។ ក្រុមប្រឹក្សាពិគ្រោះយោបល់ គឺជាអ្នកមានតួនាទីសំខាន់នៅក្នុងការត្រួតពិនិត្យមើល ផ្តល់ការយល់ព្រមនូវរាល់របាយការណ៍ គំរោងស្នើសុំនានារបស់អង្គការមុននឹងឯកសារទាំងនោះផ្ញើទៅម្ចាស់មូលនិធិ។

២. សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ គួរជាមន្ត្រី ឬបុគ្គលិកជំនាញមកពីស្ថាប័ន រឺអង្គការនានា។ អ្នកដែលត្រូវបានអញ្ជើញចូលរួម គឺជាអ្នកស្ម័គ្រចិត្ត គាំទ្រ និងជំរុញអោយទស្សនៈ គោលបំណង និងសកម្មភាពរបស់អង្គការ ដំណើរការបានប្រកបដោយជោគជ័យ ។

៣. សមាសភាពក្រុមប្រឹក្សាពិគ្រោះយោបល់របស់អង្គការ មានចំនួនយ៉ាងតិចចំនួន ៥រូប និងច្រើនបំផុតចំនួន ១១រូប ដែលស្នើឈ្មោះឡើងដោយគណៈកម្មាធិការប្រតិបត្តិ និងបោះឆ្នោតសំរេចនៅក្នុងមហាសន្និបាតរបស់អង្គការ។ ចំនួននៃសមាសភាពរបស់ក្រុមប្រឹក្សា ត្រូវតែជាចំនួនសេស (៥ រឺ៧ រឺ៩ រឺ១១) ដើម្បីទុកសំលេងអាទិភាព ជូនប្រធានក្រុមប្រឹក្សាជាអ្នកសំរេច ក្នុងករណីដែលសំលេងពីរផ្នែកមានចំនួនស្មើគ្នា ។ នៅដំណាក់កាលដំបូង ក្រោយពីការបង្កើតអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ជាផ្លូវការហើយ ក្រុមប្រឹក្សាពិគ្រោះយោបល់ មានសមាសភាពចំនួន ៥រូប ដែលជ្រើសរើសឡើងដោយសមាជិកស្ថាបនិករបស់អង្គការ។

៤. ក្រុមប្រឹក្សាពិគ្រោះយោបល់ ដឹកនាំដោយប្រធានក្រុមប្រឹក្សាមួយរូប ដែលត្រូវជ្រើសរើសឡើងតាមរយៈការបោះឆ្នោតពីសមាជិកទាំងអស់របស់ក្រុមប្រឹក្សា និងគណៈកម្មាធិការប្រិតបត្តិ និងមានអណត្តិ៣ឆ្នាំ។ ប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ មានតួនាទីដឹកនាំ និងសំរបសំរួលកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បីតំរង់ទិសអោយអនុវត្តន៍តាមទស្សនៈវិស័យ និងបេសកកម្មដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់អង្គការ ហើយត្រូវសហការជាមួយសមាជិកទាំងអស់របស់ខ្លួន ដើម្បីដោះស្រាយនូវរាល់បញ្ហាទាំងឡាយ ដែលទាក់ទងនឹងអភិបាលកិច្ចល្អរបស់អង្គការ ។ នៅក្នុងអណត្តិរបស់ខ្លួន ក្រុមប្រឹក្សាពិគ្រោះយោបល់ អាចធ្វើការតែងតាំងលេខាធិការមួយរូប ដើម្បីជួយកិច្ចការរបស់ប្រធានកុមប្រឹក្សា ។

៥. សមាសភាពរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់ ត្រូវជ្រើសរើសឡើងរៀងរាល់៣ឆ្នាំម្តង ពីមជ្ឈដ្ឋានជាតិ អន្តរជាតិ អ្នកដែលមានចំណេះដឹង បទពិសោធន៍ជ្រៅជ្រះ ដោយការស្នើបេក្ខភាពឡើងពីគណៈកម្មាធិការប្រតិបត្តិ និងបោះឆ្នោតសំរេចពីមហាសន្និបាតរបស់អង្គការ ។

៦. សមាសភាពទាំងអស់របស់ក្រុមប្រឹក្សាពិគ្រោះយោបល់ ដែលត្រូវបានលាឈប់ រឺត្រូវបានដកចេញពីតំណែងដោយការបោះឆ្នោតរបស់មហាសន្និបាត ដោយហេតុផលសមស្របផ្សេងៗ ការបំពេញបន្ថែមនូវសមាសភាពដែលនៅទំនេរនោះ ត្រូវបានធ្វើឡើង ដូចលក្ខ័ណ្ឌដែលបានចែងខាងលើ ។

## មាត្រា ១០ : ភារកិច្ច និងសមាសភាពរបស់គណៈកម្មាធិការប្រតិបត្តិ

១. គណៈកម្មាធិការប្រតិបត្តិ **Executive Committee** មានតួនាទីជាអ្នកគ្រប់គ្រង និងអនុវត្តផ្ទាល់នូវដំណើរការសកម្មភាពស្របទៅតាមទស្សនៈវិស័យ និងបេសកកម្មរបស់អង្គការ ។

២. គណៈកម្មាធិការប្រតិបត្តិ ដឹកនាំដោយប្រធានមួយរូប ដែលជាប្រធានអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍។ ប្រធានគណៈកម្មាធិការប្រតិបត្តិ ត្រូវបានជ្រើសរើសឡើងនៅរាល់ពេលដែលតំណែងនេះនៅទំនេរ តាមរយៈការប្រកួតប្រជែងសមត្ថភាព ដែលសមាសភាពរបស់គណៈកម្មការជ្រើសរើស ត្រូវបង្កើតឡើងដោយមានសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ចំនួន៣នាក់ និងសមាជិកគណៈកម្មាធិការប្រតិបត្តិចំនួន២នាក់។ ក្នុងករណីដែលប្រធានគណៈកម្មាធិការប្រតិបត្តិអសមត្ថភាព រឺប្រព្រឹត្តិកំហុសឆ្គងធ្ងន់ធ្ងរ ការដកពីតំណែង គឺជាសិទ្ធិ និងការទទួលខុសត្រូវរបស់មហាសន្និបាត។

នៅក្នុងដំណាក់កាលដែលពុំទាន់បុគ្គលិកសំរាប់អនុវត្តកម្មវិធី ប្រធានអង្គការ ត្រូវបានជ្រើសរើសឡើងដោយការព្រមព្រៀងគ្នាពីសមាជិកស្ថាបនិក សំរាប់ដឹកនាំចាត់ចែងដំណើរការអង្គការជាបណ្តោះអាសន្នរហូតដល់មានការជ្រើសរើសបុគ្គលិកសំរាប់ដំណើរការ អង្គការត្រូវធ្វើមហាសន្និបាតដើម្បីអនុម័តនូវលក្ខន្តិកៈ គោលនយោបាយសំខាន់នានា ផែនការយុទ្ធសាស្រ្ត និងជ្រើសរើសប្រធានអង្គការដើម្បីគ្រប់គ្រងដំណើរការអង្គការនៅអណតិទីមួយរបស់ខ្លួន ។

៣. គណៈកម្មាធិការប្រតិបត្តិមានសមាសភាពយ៉ាងតិចចំនួន ៥រូប ដែលជ្រើសរើសឡើង ដោយក្នុងនោះមានប្រធានអង្គការ ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ, ប្រធានកម្មវិធីនីមួយៗ និងសមាសភាពដែលនៅសល់ គឺត្រូវបានជ្រើសរើសឡើងដោយមានការឯកភាពពីក្រុមប្រឹក្សាពិគ្រោះយោបល់។ នៅដំណាក់កាលដំបូង ក្រោយពីការបង្កើតអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ជាផ្លូវការហើយ គណៈកម្មាធិការប្រតិបត្តិមានសមាសភាពចំនួន៦រូប ដែលជាសមាជិកស្ថាបនិករបស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍។

៤. សមាសភាពទាំងអស់របស់គណៈកម្មាធិការប្រតិបត្តិ មានតួនាទី និងកាតព្វកិច្ចជាអ្នកទទួលខុសត្រូវចំពោះកម្មវិធីការងារជាប្រចាំ ទំនាក់ទំនងទូទៅ កិច្ចសហការគ្នានូវគ្រប់កម្មវិធី ទាំងអស់និងធានាអោយមានការផ្លាស់ប្តូរពត៌មាន បទពិសោធន៍ការងារគ្នាជាទៀងទាត់ ។

៥. គណៈកម្មាធិការប្រតិបត្តិ មានសិទ្ធិអំណាច រឺផ្ទេរសិទ្ធិអំណាចរបស់ខ្លួនទៅអោយក្រុមអ្នកគ្រប់គ្រងរបស់កម្មវិធីនីមួយៗ ដើម្បីធ្វើការជ្រើសរើសបុគ្គលិក រឺអ្នកស្ម័គ្រចិត្តនៅក្នុងកម្មវិធីរបស់ខ្លួនទៅតាមតំរូវការចាំបាច់ ដោយការប្រកួតប្រជែង និងមានកិច្ចសន្យាការងារច្បាស់លាស់។ ការវាយតំលៃបុគ្គលិកត្រូវប្រព្រឹត្តិទៅនៅរៀងរាល់មុនដំណាច់ឆ្នាំនីមួយៗ ដែលធ្វើឡើងដោយគណៈកម្មការវាយតំលៃបុគ្គលិករបស់អង្គការ ដែលតែងតាំងដោយគណៈកម្មាធិការប្រតិបត្តិ និងមានការឯកភាពពី

ក្រុមប្រឹក្សាពិគ្រោះយោបល់ ដើម្បីសំរេចថាគួរបន្ដ រឺបញ្ឈប់កិច្ចសន្យារបស់បុគ្គលិកនីមួយៗ ។

៦. ក្នុងករណីដែលគណៈកម្មាធិការប្រតិបត្ដិមិនអាចដោះស្រាយបញ្ហា រឺធ្វើការសំរេចចិត្តណាមួយបាន គណៈកម្មាធិការប្រតិបត្ដិត្រូវធ្វើការបង្ហាញ និងបកស្រាយពន្យល់ជូនដល់ក្រុមប្រឹក្សាពិគ្រោះយោបល់ រឺក្រុមស្ថាបនិករបស់អង្គការ ដើម្បីជួយធ្វើការដោះស្រាយ រឺសំរេចចិត្ត ។

## មាត្រា ១១ថ្មី : អំពីក្រុមស្ថាបនិក

ដោយអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានផ្ដួចផ្ដើមឡើងដោយស្ថាបនិកមួយក្រុម ដូច្នេះដើម្បីទទួលស្គាល់ជាអចិន្ត្រៃយ៍នូវគំនិតផ្ដួចផ្ដើមប្រកបដោយឧត្តមគតិ មនសិកាដ៏ប្រពៃនេះ ក្រុមស្ថាបនិក **(Founder Team)** របស់អង្គការត្រូវបានបង្កើតឡើង ហើយដែលមានភារកិច្ចនៅក្នុងការឃ្លាំមើលជាប់ជាប្រចាំនូវការគ្រប់គ្រង និងអនុវត្តរាល់សកម្មភាពនានារបស់អង្គការ ព្រមជាទាំងជាអ្នកផ្ដួចផ្ដើមនូវគំរោងសកម្មភាពថ្មីៗនានា សំដៅពង្រឹង និងពង្រីកវិសាលភាពរបស់អង្គការ ស្របតាមទស្សនៈវិស័យ និងបេសកកម្មរបស់អង្គការ ។ ក្រុមស្ថាបនិកនេះ ក៏នឹងរួមបញ្ចូលផងដែរនូវបុគ្គលិក ដែលបានបំពេញការងាររយៈពេលចាប់ពី១០ខែឡើងទៅនៅក្នុងដំណាក់កាលដែលអង្គការមិនទាន់ទទួលបានជំនួយពីប្រភពនានា រឺ បុគ្គលិកដែលបានបំពេញការងាររយៈពេលចាប់ពីប្រាំឆ្នាំឡើងទៅជាមួយអង្គការ ។ ល័ក្ខណ្ឌទាំងពីរនេះ ត្រូវថ្លឹងថ្លែងជាមួយផងដែរនូវមនសិការ ការលះបង់ខ្ពស់របស់បុគ្គលិកនោះដើម្បីបុព្វហេតុដល់ការរីកចំរើនរបស់អង្គការ ។ ការផ្ដល់នូវតួនាទី ជាស្ថាបនិករបស់អង្គការ គឺធ្វើឡើងដោយមានការស្នើឡើងពីប្រធានអង្គការ និងមានការយល់ព្រមពីមហាសន្និបាតរបស់អង្គការ ។

ក្រុមស្ថាបនិក ត្រូវជ្រើសរើសប្រធានមួយរូប ដោយបោះឆ្នោតដោយស្ថាបនិកទាំងអស់របស់អង្គការ ដើម្បីបំពេញការងារជាអ្នកសំរបសំរួលជាមួយសមាជិកផ្សេងៗទៀតរបស់ខ្លួន ។ ប្រធានក្រុមស្ថាបនិក បំពេញការងារដោយគ្មានអណត្តិ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងទៀតនៅក្នុងរង្វង់ក្រុមស្ថាបនិកទាំងមូល ទើបការផ្លាស់ប្ដូរប្រធាន អាចព្រឹត្តិទៅបាន ។

គ្រប់ស្ថាបនិកទាំងអស់របស់អង្គការ មិនត្រូវអាចបានដកសិទ្ធិចេញពីក្រុមស្ថាបនិកនេះបានឡើយ លើកលែងតែសមាជិករូបនោះ ធ្វើការលាលែងជាលាយល័ក្ខអក្សរដោយខ្លួនឯងផ្ទាល់ដើម្បីជូនដំណឹងទៅប្រធានក្រុមស្ថាបនិក ព្រមទាំងចំលងជូនក្រុមប្រឹក្សាពិគ្រោះយោបល់ និងគណៈកម្មាធិការប្រតិបត្ដិរបស់អង្គការ ។

# ជំពូក ៤

# មហាសន្និបាត និងការប្រជុំ

## មាត្រា ១២ : មហាសន្និបាតរបស់អង្គការ

មហាសន្និបាត ជាស្ថាប័នសំរេចចិត្តខ្ពស់បំផុតដែលចូលរួមដោយគ្រប់បុគ្គលិក សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ និងសមាជិកក្រុមស្ថាបនិកទាំងអស់របស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍។ មហា

សន្និបាតរបស់អង្គការ មានមហាសន្និបាតសាមញ្ញ ដែលប្រព្រឹត្តិទៅនៅរៀងរាល់មួយឆ្នាំម្តង និងមហាសន្និបាតវិសាមញ្ញ រៀបចំឡើងនៅក្នុងករណីពិសេសចាំបាច់បន្ទាន់តាមការអញ្ជើញរបស់ប្រធានអង្គការ រឺ សំណូមពរពីរភាគបីពីសមាជិកគណៈកម្មាធិការប្រតិបត្តិ។ មហាសន្និបាតរបស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍មានកាតព្វកិច្ចដើម្បីពិភាក្សា និងអនុម័ត :

- សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ និងសមាជិកក្រុមស្ថាបនិក
- ពិនិត្យ និងវាយតំលៃលើរបាយការណ៍សកម្មភាព របាយការណ៍ហិរញ្ញវត្ថុ
- គំរោងផែនការសកម្មភាព និងថវិកា ព្រមទាំងយុទ្ធសាស្រ្តសំរាប់អនុវត្តនៅឆ្នាំបន្ទាប់
- ខ្លឹមសារគោលនយោបាយ គោលការណ៍នានា ការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់អង្គការ
- ការរួមសម្ព័ន្ធភាព ការផ្អាក រឺការរំលាយអង្គការ និងការចាត់ចែងទ្រព្យសម្បត្តិនៅពេលអង្គការត្រូវរំលាយ
- ពិនិត្យដោះស្រាយបញ្ហា ករណីផ្សេងៗទៀតដែលកើតមានឡើងដោយយថាហេតុ។

សេចក្តីសំរេចរបស់មហាសន្និបាតសាមញ្ញ និងមហាសន្និបាតវិសាមញ្ញ មានតំលៃគតិយុត្តិដូចគ្នា ដោយឈរលើមូលដ្ឋាន នៃការអនុម័តដោយសំលេងយ៉ាងតិចពីរភាគបី លើកូរ៉ុមចូលរួមប្រជុំយ៉ាងតិចបីភាគបួន នៃចំនួនសមាជិកដែលត្រូវចូលរួម និងត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ និងប្រធានគណៈកម្មាធិការប្រតិបត្តិរបស់អង្គការ។

## មាត្រា ១៣ : ការប្រជុំរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់

ក្រុមប្រឹក្សាពិគ្រោះយោបល់ ត្រូវជួបប្រជុំគ្នាជាទៀងទាត់ រៀងរាល់១ត្រីមាសម្តង។ ការប្រជុំនេះត្រូវប្រព្រឹត្តិទៅនៅក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សា ដោយមានការចូលរួមពីសមាជិកទាំងអស់របស់ក្រុមប្រឹក្សា និងប្រធានគណៈកម្មាធិការប្រតិបត្តិ ដែលយ៉ាងហោចណាស់ត្រូវមានចំនួនហាសិបភាគរយនៃចំនួនសមាជិក ដែលត្រូវចូលរួមទាំងអស់ទើបអាចដំណើរការប្រជុំបាន។ សមាជិកក្រុមស្ថាបនិករបស់អង្គការត្រូវបានអញ្ជើញអោយចូលរួមនៅក្នុងការប្រជុំនេះ ប៉ុន្តែមិនរាប់បញ្ចូលទៅក្នុងកូរ៉ុមដើម្បីដំណើរការប្រជុំឡើយ ។

ការប្រជុំរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់ ត្រូវបានផ្តួចផ្តើមឡើងដោយប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ រឺប្រធានគណៈកម្មាធិការប្រតិបត្តិ រឺសមាជិកក្រុមប្រឹក្សាស្ថាបនិក ដែលមានគោលដៅសំខាន់ គឺជាវេទិកាពិគ្រោះ និងផ្តល់យោបល់ក្នុងការរៀបចំផែនការ យុទ្ធសាស្រ្ត ការកែលំអការគ្រប់គ្រង ការអនុវត្តន៍ និងផ្តល់នូវសេចក្តីយល់ព្រមទៅលើរបាយការណ៍ គំរោងស្នើសុំថវិកានានា មុននឹងបញ្ជូនទៅម្ចាស់មូលនិធិ។

លិខិតអញ្ជើញ ដោយមានភ្ជាប់ជាមួយរបៀបវីរៈប្រជុំច្បាស់លាស់ ត្រូវរៀបចំឡើងដោយប្រធានគណៈកម្មាធិការប្រតិបត្តិ និងឯកភាពយល់ព្រមដោយប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ ដើម្បីបញ្ជូនទៅដល់គ្រប់សមាជិកដែលត្រូវចូលរួមប្រជុំទាំងអស់ រួមទាំងសមាជិកក្រុមស្ថាបនិករបស់អង្គការផងដែរ អោយបានយ៉ាងតិចចំនួន ៥ថ្ងៃ មុនថ្ងៃប្រជុំមកដល់ ។

ប្រធានគណៈកម្មាធិការប្រតិបត្តិ អាចស្នើសុំអោយសមាជិកណាផ្សេងទៀតរបស់គណៈកម្មាធិការ ចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់បាន ដោយគ្រាន់តែបញ្ជូនឈ្មោះសមាជិកនោះទៅកាន់ក្រុមប្រឹក្សាពិគ្រោះយោបល់ អោយបានមុនយ៉ាងហោចណាស់បីថ្ងៃ មុនថ្ងៃប្រជុំ ។

**មាត្រា ១៤ : ការប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ**

គណៈកម្មាធិការប្រតិបត្តិ ត្រូវធ្វើការប្រជុំសមាជិករបស់ខ្លួន នៅរៀងរាល់១ខែម្តង ដើម្បីពិភាក្សា និងសំរេចនូវរាល់ដំណើរការគ្រប់គ្រង អនុវត្ត និងវឌ្ឍនៈភាពរបស់គំរោងកម្មវិធី ។

ការប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់ប្រធានគណៈកម្មាធិការ ដោយមានការចូលរួមពីគ្រប់សមាជិកទាំងអស់របស់គណៈកម្មាធិការប្រតិបត្តិ ។

បុគ្គលិកពាក់ព័ន្ធដទៃទៀតរបស់កម្មវិធីនីមួយៗ អាចត្រូវបានអញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ ដោយយោងទៅលើប្រធានបទនៃកិច្ចប្រជុំ និងមានការឯកភាពពីប្រធានគណៈកម្មាធិការ ។

**មាត្រា ១៥ : ការប្រជុំ របស់កម្មវិធីនានា**

កម្មវិធីនីមួយៗ របស់គណៈកម្មាធិការប្រតិបត្តិ នៃអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ អាចធ្វើការប្រជុំបុគ្គលិកកម្មវិធីរបស់ខ្លួន ទៅតាមតំរូវការជាក់ស្តែង ដើម្បីពិភាក្សាពីដំណើរការនៃការងារ កំណត់ពីឧបសគ្គ និងស្វែងរកចំនុចកែលំអ ដើម្បីធ្វើអោយមានភាពប្រសើរឡើង នៅក្នុងការគ្រប់គ្រង និងអនុវត្តកម្មវិធីរបស់ខ្លួន ។

**មាត្រា ១៦ : ការប្រជុំ វិសិក្ខាសាលាផ្សេងៗទៀតរបស់អង្គការ**

ក្រុមប្រឹក្សាពិគ្រោះយោបល់ ក្រុមស្ថាបនិក គណៈកម្មាធិការប្រតិបត្តិ និងកម្មវិធីនីមួយៗរបស់អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ អាចរៀបចំការប្រជុំពិសេស វិសិក្ខាសាលាដោយឡែកផ្សេងៗទៀត ដែលពុំមានចែងក្នុងមាត្រា១៣ មាត្រា១៤ និងមាត្រា១៥ ខាងលើ ទៅតាមស្ថានភាព និងកាលៈទេសៈជាក់ស្តែង ។

## ជំពូក ៥

## អំពីមូលនិធិ និងការគ្រប់គ្រងមូលនិធិ_ថវិកា

**មាត្រា ១៧ : ប្រភពមូលនិធិ**

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ នឹងទទួលយកនូវមូលនិធិ ដើម្បីអនុវត្តគំរោងកម្មវិធីរបស់ខ្លួន ពីការបង់វិភាគទានពីសមាជិកស្ថាបនិក រឺបុគ្គលិករបស់អង្គការ ព្រមទាំងពីគ្រប់ប្រភពផ្តល់ជំនួយនានា ដែលមានគោលដៅស្របតាមគោលការណ៍ ទស្សនៈវិស័យ បេសកកម្ម និងសកម្មភាពការងាររបស់អង្គការ ដូចមានចែងក្នុងជំពូក២ មាត្រា៤ មាត្រា៥ មាត្រា៦ និងមាត្រា៧ នៃលក្ខន្តិកៈនេះ លើកលែងតែការផ្តល់ជំនួយពី

គណបក្សនយោបាយ រឺពីប្រភពដែលបំរើអោយនយោបាយរបស់ជន រឺក្រុមណាមួយ រឺពីប្រភពដែលផ្តល់មូលនិធិក្នុងរូបភាពជាប្រាក់កម្ចី រឺឥណទាន ដែលអង្គការបដិសេធន៍មិនទទួលយកដាច់ខាត ។

**មាត្រា ១៨ : ការគ្រប់គ្រងមូលនិធិ ថវិកា**

មូលនិធិដែលទទួលបានពីម្ចាស់ជំនួយនានា ត្រូវរក្សាទុកនៅក្នុងគណនី នៃធនាគារដែលត្រូវជ្រើសរើសឡើងដោយគណៈកម្មាធិការប្រតិបត្តិ និងឯកភាពដោយក្រុមប្រឹក្សាពិគ្រោះយោបល់។ ការដកថវិកាពីធនាគារយកមកប្រើប្រាស់ក្នុងគោលដៅបំរើអោយការអនុវត្តន៍កម្មវិធីនានារបស់អង្គការ ប្រព្រឹត្តិទៅបានដោយមានការចុះហត្ថលេខាយ៉ាងតិចចំនួនពីរនាក់ ក្នុងចំណោមបីនាក់ គឺប្រធានអង្គការ រឺអនុប្រធានអង្គការ និងប្រធានរដ្ឋបាល-ហិរញ្ញវត្ថុ រឺប្រធានផ្នែកកម្មវិធីណាមួយ។ រាល់ការដកថវិកា ដែលមានបរិមាណទឹកប្រាក់ចាប់ពី ១០០០ ដុល្លារ (មួយពាន់ដុល្លារ) ឡើងទៅ ប្រធានគណៈកម្មាធិការ ត្រូវជូនដំណឹង និងយល់ព្រមពីក្រុមប្រឹក្សាពិគ្រោះយោបល់ជាមុនសិន។ គណៈកម្មាធិការប្រតិបត្តិ ត្រូវទទួលខុសត្រូវចំពោះរាល់ការសំរេចចិត្ត និងការអនុម័តណាមួយទៅលើការចំណាយថវិកា រៀបចំកិច្ចសន្យា និងកិច្ចព្រមព្រៀងនានា ។

ទំរង់ការ និងបែបបទនៃការប្រើប្រាស់មូលនិធិរបស់អង្គការ ត្រូវបានរៀបចំឡើងដោយមានការព្រមព្រៀងគ្នារវាងគណៈកម្មាធិការប្រតិបត្តិ ជាមួយម្ចាស់ជំនួយដោយឡែក១ ។

រាល់បញ្ជីគណនេយ្យរបស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យហិរញ្ញវត្ថុឯករាជ្យពីខាងក្រៅ រៀងរាល់មួយឆ្នាំម្តង និងធ្វើរបាយការណ៍លទ្ធផល ដើម្បីដាក់ជូនទៅក្រុមប្រឹក្សាពិគ្រោះយោបល់ និងម្ចាស់ជំនួយ ។

## ជំពូក ៦
## ការចប់អណត្តិរបស់អង្គការ

**មាត្រា ១៩ : ការរំសាយអង្គការ**

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ នឹងត្រូវបានប្រកាសផ្អាក រឺរំសាយដោយមានការឯកភាពនៅក្នុងមហាសន្និបាតរបស់អង្គការ នៅក្នុងស្ថានភាពដែលអង្គការគ្មានលទ្ធភាពខាងផ្នែកថវិកា ដើម្បីបន្តដំណើរការសកម្មភាពរបស់ខ្លួនបាន រឺស្ថិតនៅក្នុងកាលៈទេសៈដែលមិនអាចធានាបាននូវសន្តិសុខ សុវត្ថិភាព ដល់អង្គការ ។

ការប្រកាសរំសាយនេះ ត្រូវធ្វើឡើងជាលាយល័ក្ខអក្សរដែលមានចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ និងប្រធានគណៈកម្មាធិការប្រតិបត្តិ របស់អង្គការ និងផ្ញើជូនទៅស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល អង្គភាព ស្ថាប័ន អង្គការ ប្រភពផ្តល់ជំនួយពាក់ព័ន្ធទាំងឡាយ ដើម្បីជូនជ្រាបជាផ្លូវការ ។

**មាត្រា ២០ : ការចាត់ចែងទ្រព្យសម្បត្តិ**

ក្នុងករណីដែលអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានប្រកាសផ្អាក រឺរំសាយ ដូចមានចែងក្នុងមាត្រា១៩ ទ្រព្យសម្បត្តិទាំងអស់របស់អង្គការ នឹងត្រូវបានបែងចែកប្រគល់ទៅអោយអង្គការ រឺស្ថាប័ន

ដែលមានគោលដៅ និងបេសកកម្មប្រហាក់ប្រហែលនឹងអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ដោយមានការសំរេចរបស់មហាសន្និបាត ។

ការបែងចែកទ្រព្យសម្បត្តិទាំងនេះ ក៏នឹងត្រូវបានជូនដំណឹងជាលាយល័ក្ខអក្សរ ដែលមានចុះហត្ថលេខា ដោយប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ និងប្រធានគណៈកម្មាធិការប្រតិបត្តិរបស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ និងតំណាងអង្គការ រឺស្ថាប័ន ដែលជាអ្នកទទួលទ្រព្យសម្បត្តិនេះ ដើម្បីផ្ញើជូនទៅស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល អង្គភាព ស្ថាប័ន អង្គការ ប្រភពផ្តល់ជំនួយពាក់ព័ន្ធទាំងឡាយ ដើម្បីជូនជ្រាបជាផ្លូវការ ។

## ជំពូក ៧

## អវសានបញ្ញត្តិ

### មាត្រា ២១ : ការរៀបចំគោលការណ៍ និងបទបញ្ញត្តិផ្សេងៗ

ដើម្បីអោយការបំពេញបេសកកម្មរបស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ប្រកបដោយភាពរលូន និងមានប្រសិទ្ធិភាព គណៈកម្មាធិការប្រតិបត្តិ មានកាតព្វកិច្ចរៀបចំ និងអនុម័តបន្ថែមទៀតនូវគោលការណ៍ និតិវិធី រឺបទបញ្ញត្តិផ្សេងៗទៀត ដែលស្របតាមលក្ខន្តិកៈនេះ ដោយមានការពិគ្រោះយោបល់ និងឯកភាពជាមួយក្រុមប្រឹក្សាពិគ្រោះយោបល់ ។

### មាត្រា ២២ : វិសោធនកម្ម នៃលក្ខន្តិកៈ

ក្នុងករណីចាំបាច់ និងស្របទៅតាមស្ថានភាពជាក់ស្តែងនៃការបំពេញបេសកកម្មរបស់ខ្លួន លក្ខន្តិកៈនេះអាចធ្វើការផ្លាស់ប្តូរ បន្ថែម រឺលុបចោលនូវខ្លឹមសារ រឺមាត្រាណាមួយបាន ដែលអនុម័តដោយមហាសន្និបាតរបស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ។

អង្គភាព ស្ថាប័ន អង្គការ និងប្រភពផ្តល់ជំនួយដែលពាក់ព័ន្ធទាំងអស់ ត្រូវបានទទួលនូវអត្ថបទកែប្រែលក្ខន្តិកៈនេះជាផ្លូវការ ដែលមានចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការប្រតិបត្តិ ។

### មាត្រា ២៣ : និរាករណ៍ នៃបទបញ្ញត្តិផ្សេងៗ

រាល់គោលការណ៍ និតិវិធី និងបទបញ្ញត្តិទាំងឡាយណា ដែលមិនស្របតាម រឺផ្ទុយពីលក្ខន្តិកៈនេះ ត្រូវទុកជានិរាករណ៍ ។

### មាត្រា ២៤ : ការចូលជាធរមាននៃលក្ខន្តិកៈ

លក្ខន្តិកៈនេះ មានប្រសិទ្ធិភាពសំរាប់អនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

វិសោធនកម្មលើកទី១ លើលក្ខន្តិកៈអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានអនុម័តយល់ព្រមដោយមហាសន្និបាតរបស់អង្គការ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦។

**ហត្ថលេខា**

**ប្រធានអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍**

**សួន សុខេង**

## ឧសម្ព័ន្ធ១

## សញ្ញាសំគាល់ អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍